# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យសច្ចាប្រណិធាន
## របស់អ្នកប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ (អ៊ីប៉ូក្រាត)

នៅពេលដែលត្រូវបានអនុញ្ញាត អោយបំពេញភារកិច្ចក្នុងមុខវិជ្ជាជីវៈជាគ្រូពេទ្យ យើងខ្ញុំ សូមសន្យា និង សូមសច្ចាយ៉ាងឧឡារិកថា នឹងគោរពតាមក្រមសីលធមិគ្រូពេទ្យ ដោយប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវ ភាពស្មោះត្រង់ និងគោលការណ៍សីលធមិ ភាពសុច្ចរិត យុត្តិធមិ និងភក្តីភាព ក្នុងការប្រកបវិជ្ជាជីវៈ អោយមាន ប្រសិទ្ធភាព ធានាការពារកិត្តិយស និងឥស្សរះភាពរបស់វិជ្ជាជីវៈវេជ្ជសាស្ត្រ ។

កង្វល់ទីមួយរបស់យើងខ្ញុំ គឺ ការធ្វើអោយប្រសើរឡើង នូវការរក្សា និងការលើកកំពស់សុខភាពរាងកាយ និងស្មារតី ជូនចំពោះ បុគ្គល និងសង្គម ។ យើងខ្ញុំ នឹងគោរពមនុស្សគ្រប់រូប ព្រមទាំងគោរព ស្វ័យភាព និងឆន្ទៈរបស់ពួកគេ ដោយពុំមានការបែងចែកវណ្ណៈ ឬ ជំនឿអ្វីឡើយ ។

យើងខ្ញុំ នឹងធ្វើអន្តរាគមន៍គ្រប់បែបយ៉ាង ដើម្បីការពារអ្នកទាំងឡាយ ដែលត្រូវចុះខ្សោយ ដែលត្រូវរងគ្រោះ ឬ ដែលទទួលការគំរាមកំហែង ដល់បូរណភាពរាងកាយ ឬ ប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ពួកគេ ។ ទោះស្ថិតក្រោមការបង្ខិតបង្ខំយ៉ាងណាក្តី យើងខ្ញុំ នឹងមិនយកចំណេះដឹងរបស់ខ្លួន ទៅប្រើប្រាស់អោយផ្ទុយនឹងច្បាប់របស់មនុស្សជាតិជាដាច់ខាត ។

យើងខ្ញុំ នឹងផ្តល់ពតិមានដល់អ្នកជំងឺ អំពីមូលហេតុ និងផលវិបាកផ្សេងៗ នៃការសំរេចចិត្តនានា ដែលនឹងត្រូវធ្វើឡើង ចំពោះរូបគេ ។ យើងខ្ញុំ នឹងមិនបំភ័ន្ត នូវការទុកចិត្តរបស់ពួកគេ និងមិនឆ្លៀតឱកាស ប្រើប្រាស់សិទ្ធិអំណាច ដែលបានទទួលនៅក្នុងកាលៈទេសៈនោះ ដើម្បីធ្វើការបង្ខិតបង្ខំ ដល់មនសិការរបស់ពួកគេឡើយ ។ យើងខ្ញុំ នឹងធ្វើការថែទាំអោយអស់ពីចិត្តពីថ្លើម ដល់ជនក្រីក្រ និង ចំពោះជនទាំងឡាយណា ដែលមកពឹងពាក់យើងខ្ញុំ ។ យើងខ្ញុំ នឹងមិនបណ្តែតបណ្តោយខ្លួន អោយស្ថិតនៅក្រោមឥទ្ធិពល នៃការស្រេក ឃ្លានលាភសក្ការៈ ឬ ការស្វែងរកភាពរុងរឿងផ្ទាល់ខ្លួនឡើយ ។

នៅក្នុងពេលបានចូលជិត ស្និតស្នាលជាមួយមនុស្សទាំងឡាយ នៅពេលបានចូលទៅក្នុងគេហដ្ឋាន របស់អ្នកជំងឺ យើងខ្ញុំ នឹងគោរព រក្សាការសំងាត់ទាំងឡាយ ដែលយើងខ្ញុំបានដឹង បានឮ និងបានឃើញ ហើយឥរិយាបថរបស់យើងខ្ញុំ នឹងមិនធ្វើអោយប៉ះពាល់ ដល់សីលធមិជាដាច់ខាត ។ យើងខ្ញុំ នឹងធ្វើគ្រប់បែបយ៉ាង ដើម្បីបន្ថយការឈឺចាប់ទាំងឡាយ ។

យើងខ្ញុំ នឹងមិនបង្កអោយមានមរណៈភាព ជាដាច់ខាត ។

យើងខ្ញុំ នឹងរក្សាឯករាជ្យភាព អោយបានខ្ជាប់ខ្ជួន ក្នុងការបំពេញភារៈកិច្ចរបស់ខ្លួន ។ យើងខ្ញុំ នឹងមិនផ្តើមធ្វើអ្វីមួយ ដែលហួសពីសមត្ថភាពរបស់ខ្លួនឡើយ ។ យើងខ្ញុំ នឹងខិតខំ ពង្រឹង ព្រមទាំងធ្វើអោយរឹតតែសុក្រិត្យថែមទៀតនូវសមត្ថភាពរបស់ខ្លួន ដើម្បីធានា អោយការបំរើសេវាទាំងឡាយ ដែលអ្នកជំងឺត្រូវការ មានប្រសិទ្ធិភាពពិតប្រាកដ ។

យើងខ្ញុំ នឹងជួយយកអាសារ ដល់សហភាតរៈទាំងឡាយ ព្រមទាំងដល់គ្រួសាររបស់ពួកគេ នៅគ្រប់ពេលជួបការលំបាក ។

សូមអោយមនុស្សទូទៅ និងសហភាតរៈទាំងអស់ គាំទ្រ និង អោយតម្លៃដល់រូបយើងខ្ញុំ ប្រសិនណា ជាយើងខ្ញុំមានការស្មោះត្រង់ និងអនុវត្តតាមពាក្យសន្យាទាំងនេះ និង

សូមអោយយើងខ្ញុំ ត្រូវអាប់ឱនកេរ្តិ៍ឈ្មោះ ព្រមទាំងទទួលការមើលងាយមើលថោក ប្រសិនណា ជាយើងខ្ញុំ បានក្បត់នឹងពាក្យសច្ចាទាំងអស់នេះ ។

ធ្វើនៅ.........................................ថ្ងៃទី.........ខែ.................ឆ្នាំ ២០......

**ហត្ថលេខាសាមីខ្លួន**

បានឃើញ និងបញ្ជាក់ថា

សាមីខ្លួន បានសច្ចាប្រណិធាន និងចុះហត្ថលេខានៅចំពោះមុខតំណាង

ក្រុមប្រឹក្សាគណៈគ្រូពេទ្យ.........................................ពិតមែន ។

..................................ថ្ងៃទី...........ខែ...................ឆ្នាំ ២០.....

**ជ.ក្រុមប្រឹក្សាគណៈគ្រូពេទ្យ**...............................................

**ប្រ ធា ន**